A Royal Women's Hospital
**Well Women's Publication**

Women's Health Matters

ប័ណ្ណពត៌មានអំពីការមានផ្ទៃពោះនិងការសំរាលកូន : ខែមេសា ឆ្នាំ 2002

# ការថែទាំគភ៌រួមគ្នានៅមុនពេលសំរាលកូន នៅឯមន្ទីរពេទ្យស្ត្រី (royal women's hospital)

## តើអ្វីទៅដែលជាការថែទាំគភ៌រួមគ្នានៅមុនពេលសំរាលកូន ?

ការថែទាំរួមគ្នានៅមុនពេលសំរាលកូនមានន័យថា ក្នុងអម្លុងពេលមានផ្ទៃពោះ អ្នកអាចអញ្ជើញទៅជួបមន្ទីរពេទ្យ និងគ្រូពេទ្យ GP ឬឆ្មបសហគមន៍របស់អ្នក។ អ្នកទាំងអស់នេះ នឹង"រួមចំណែកផ្តល់ការថែទាំជូនអ្នក"។ អ្នកនឹងសំរាលកូននៅឯមន្ទីរពេទ្យស្ត្រី (Royal Women's Hospital) នៅ Carlton ។

## តើការថែទាំគភ៌រួមគ្នានៅមុនពេលសំរាលកូន មានប្រយោជន៍អ្វីខ្លះទៅ ?

ប្រយោជន៍ចំបងគឺថា ជាធម្មតា អ្នកអាចជួបនឹងអ្នកផ្តល់ការថែទាំដដែល នៅពេញពេលមានផ្ទៃពោះរបស់អ្នក។ អ្នកនេះប្រហែលជាវេជ្ជបណ្ឌិតក្នុងតំបន់អ្នក ឬ ឆ្មបសហគមន៍មួយរូប។ នេះមានន័យថា អ្នកអាច

- ទៅជួបអ្នកផ្តល់ការថែទាំម្នាក់ ដែលនៅជិតផ្ទះអ្នកជាងគេ
- បន្តទៅជួបអ្នកផ្តល់ការថែទាំដដែលនេះ ក្រោយពីសំរាលកូនហើយ។

ការថែទាំរួមគ្នា ក៏មានផងដែរសំរាប់ស្ត្រីដែលចូលរួមនៅក្នុង Family Birth Centre (មជ្ឈមណ្ឌលសំរាលកូនរបស់គ្រួសារ) និង Hospital Community Clinics (គ្លីនិកសហគមន៍របស់មន្ទីរពេទ្យ)។

អ្នកផ្តល់ការថែទាំរួមគ្នា អាចគិតថ្លៃដែលមិនចេញឲ្យដោយ Medicare ឡើយ។ ការយកថ្លៃនេះ នឹងមានចំនួនខុសគ្នា នៅក្នុងចំណោមអ្នកផ្តល់ការថែទាំទាំងឡាយ។ សូមពិភាក្សាសំណួរណាមួយ អំពីបញ្ហានេះ ជាមួយអ្នកផ្តល់ការថែទាំដែលអ្នករើសយក។

THE ROYAL WOMEN'S HOSPITAL

មន្ទីរពេទ្យស្ត្រីក៏ចាត់ចែង **Community Clinics** (គ្លីនិកសហគមន៍)ផងដែរ ដែលធ្វើប្រតិបត្តិការដោយបុគ្គលិកមន្ទីរពេទ្យ ហើយគ្មានគិតថ្លៃទេ។ អ្នកអាចរើសយកការណាត់ជួបរបស់អ្នកនៅឯមន្ទីរពេទ្យ នៅឯគ្លីនិកសហគមន៍មួយ ជាជំនួសឲ្យការអញ្ជើញទៅកាន់មន្ទីរពេទ្យ បើការធ្វើយ៉ាងនេះធ្វើឲ្យកាន់តែងាយស្រួលឡើងចំពោះអ្នក។ គ្លីនិកទាំងនេះ មានទីតាំងនៅ Kensington, Coburg និង Moonee Ponds ។

**ប័ណ្ណពត៌មានអំពីការមានផ្ទៃពោះនិងការសំរាលកូន : ខែមេសា ឆ្នាំ 2002**
**ការថែទាំគភ៌រួមគ្នានៅមុនពេលសំរាលកូន នៅឯមន្ទីរពេទ្យស្ត្រី** (តពីទំព័រមុន)

## តើវេជ្ជបណ្ឌិតដែលខ្ញុំជួបនៅពេលឥឡូវនេះ អាចផ្តល់ការថែទាំឲ្យខ្ញុំដែរឬទេ ?

ដើម្បីផ្តល់ការថែទាំរួមគ្នា វេជ្ជបណ្ឌិត / ឆ្មបក្នុងតំបន់អ្នក ត្រូវតែទទួលស្គាល់ជាផ្លូវការដោយមន្ទីរពេទ្យស្ត្រី។ បើវេជ្ជបណ្ឌិត / ឆ្មបក្នុងតំបន់អ្នក គ្មានការទទួលស្គាល់នេះទេ គេអាចដាក់ពាក្យសុំការទទួលស្គាល់ជាផ្លូវការ នៅឯមន្ទីរពេទ្យស្ត្រី។

នៅពេលចុះឈ្មោះថែទាំរួមគ្នា អ្នកនឹងទទួលឯកសារកត់ត្រាការមានផ្ទៃពោះមួយ។ សូមកាន់យកឯកសារនេះទៅជាមួយអ្នក នៅពេលទៅជួបទាំងអស់ ក្នុងអម្លុងពេលមានផ្ទៃពោះរបស់អ្នក និងនៅពេលដែលអ្នកអញ្ជើញទៅសំរាលកូន។ ការធ្វើដូចនេះនឹងធានាថា បញ្ជីកត់ត្រាអំពីការថែទាំគភ៌និងពត៌មានរបស់អ្នក មានភាពត្រឹមត្រូវនិងទាន់ពេល។

អ្នកអាចរើសយកការបញ្ឈប់ការថែទាំរួមគ្នា នៅពេលណាមួយក៏បានដែរ ក្នុងអម្លុងពេលអ្នកមានផ្ទៃពោះ ដោយទាក់ទងអ្នកសំរបសំរួលថែទាំរួមគ្នា។ បើអ្នកកើតមានបញ្ហាក្នុងអម្លុងពេលដែលអ្នកមានផ្ទៃពោះ ការថែទាំរួមគ្នាប្រហែលជាមិនសមរម្យទេ ហើយការថែទាំអ្នក អាចនឹងប្រគល់ទៅឲ្យគ្លីនិករបស់មន្ទីរពេទ្យស្ត្រីវិញ។

## ការណាត់ជួប

**ដើម្បីទទួលពត៌មាននិងធ្វើការណាត់ជួប សូមទាក់ទង Shared Care Coordinator (អ្នកសំរបសំរួលថែទាំរួមគ្នា) តាមទូរស័ព្ទលេខ (03) 8345-2129 ។**

A Royal Women's Hospital
**Well Women's Publication**

Women's Health Matters

ប័ណ្ណពត៌មានអំពីការមានផ្ទៃពោះនិងការសំរាលកូន : ខែមេសា ឆ្នាំ 2002

# គំរោងពេលទៅជួប នៃការថែទាំគភ៌រួមគ្នានៅមុនពេល សំរាលកូន

សូមកត់សំគាល់ថា  នេះជាគំរោងពេល**ស្តង់ដារ**មួយនៃការទៅជួបទាំងពួង។ គំរោងពេលទាំងនេះ អាចខុសៗគ្នា ដោយអាស្រ័យទៅតាមសេចក្តីត្រូវការរបស់អ្នក។

| | |
|---|---|
| **8-12 អាទិត្យ:** | ទៅជួបជាដំបូង នៅឯមន្ទីរពេទ្យស្ត្រី ឬគ្លីនិកសហគមន៍មួយរបស់មន្ទីរពេទ្យ<br>Pregnancy Booking Clinic (គ្លីនិកត្រៀមសំរាប់ការមានផ្ទៃពោះ) ដើម្បីជួបឆ្មប និងអ្នកឯកទេសមួយរូប។<br>*តេស្តពិនិត្យពិច័យមុនពេលសំរាលកូន* |
| **16 អាទិត្យ:** | ទៅជួបវេជ្ជណ្ឌិត ឬ ឆ្មបក្នុងតំបន់អ្នក<br>*តេស្តពិនិត្យពិច័យសេរ៉ូមម្តាយ (នៅពេលនេះ គឺស្រេចនឹងចិត្តទេ)* |
| **18-20 អាទិត្យ:** | *Ultrasound* |
| **20 អាទិត្យ:** | ទៅជួបវេជ្ជបណ្ឌិត ឬ ឆ្មបក្នុងតំបន់អ្នក |
| **26 អាទិត្យ:** | ទៅជួបវេជ្ជបណ្ឌិត ឬ ឆ្មបក្នុងតំបន់អ្នក |
| **26 អាទិត្យ:** | ការណាត់ជួបនឹងមន្ទីរពេទ្យស្ត្រី ឬ គ្លីនិកសហគមន៍<br>ការជួបសំភាសន៍នៅមុនពេលចូលក្នុងមន្ទីរពេទ្យ ដើម្បីពិភាក្សាអំពីផែនការចេញពីមន្ទីរពេទ្យ<br>*GCT រកមើលរោគទឹកនោមផ្អែម, Hb, អង្គបដិបក្ខ Rh (បើចាំបាច់)* |
| **30 អាទិត្យ:** | ទៅជួបវេជ្ជបណ្ឌិត ឬ ឆ្មបក្នុងតំបន់អ្នក |
| **33 អាទិត្យ:** | ទៅជួបវេជ្ជបណ្ឌិត ឬ ឆ្មបក្នុងតំបន់អ្នក |
| **36 អាទិត្យ:** | ការណាត់ជួបនឹងមន្ទីរពេទ្យស្ត្រី ឬ គ្លីនិកសហគមន៍<br>អ្នកឯកទេស<br>*តេស្ត GBS, អង្គបដិបក្ខ Rh (បើចាំបាច់)* |
| **38 អាទិត្យ:** | ទៅជួបវេជ្ជបណ្ឌិត ឬ ឆ្មបក្នុងតំបន់អ្នក |

| | |
|---|---|
| **40 អាទិត្យ:** | ទៅជួបវេជ្ជបណ្ឌិត ឬ ឆ្មបក្នុងតំបន់អ្នក |
| **41 អាទិត្យ:** | មន្ទីរពេទ្យស្ត្រី<br>អ្នកឯកទេស (បើចាំបាច់) |

**វេជ្ជបណ្ឌិត / ឆ្មបថែទាំរួមគ្នារបស់អ្នក គឺ:**

..............................................................................................................................